FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ

ឆ្នាំទី ៤ លេខ ៣៧ ខែមិថុនា ឆ្នាំ២០០៥

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

A Publication of the Cambodian Agricultural Research and Development Institute



# ពូជសណ្តែកបាយ "កាឌីជ័យ"

ពូជសណ្តែកបាយកាឌីជ័យ "CARDI Chey" ត្រូវបានបញ្ចេញដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (កាឌី) នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទនាឆ្នាំ ២០០១ បន្ទាប់ពីបានធ្វើការពិសោធន៍អស់រយៈពេល ប្រាំមួយរដូវកន្លងមក ។ ពូជនេះមានប្រភពដើមចេញពីស្រទ្បាយ VC 1973A របស់មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ដំណាំបន្លែអាស៊ី AVRDCដែលស្ថិតនៅប្រទេសតៃវ៉ាន់។

## លក្ខណៈពិសេសៗរបស់ពូជសណ្តែកបាយ "កាឌីជ័យ"

**សណ្តែកបាយ "កាឌីជ័យ"** ចេញផ្ការយៈពេល ៣៥ ថ្ងៃ និងទុំប្រមូលផលលើកទីមួយរយៈពេល ៥៥ ថ្ងៃ បន្ទាប់ពីដាំ។ ដើមដងមានពណ៌បៃតង រាងជ្រុងឈរត្រង់ កម្ពស់ដើមប្រែប្រួលពី ៥០-៧៣ ស.ម បែកមែកពី ២-៤ មែក។ នៅលើដើម និងមែកមានរោមតូចៗឆ្មារ។ ប្រព័ន្ធឫស មានឫសកែវ និងឫសរយាងដែលអាចចាក់ចូលទៅក្នុងដីជម្រៅ ពី ៥០-៦០ ស.ម ប៉ុន្តែ ៨០ ភាគរយ នៃប្រព័ន្ធឫសស្ថិតនៅជម្រៅពី ៥-២០ ស.ម។ នៅលើឫសមានកំពកឫសតូចៗ បង្កើតឡើងដោយវត្តមាននៃបាក់តេរីមួយចំនួនក្នុងពួករីហ្សូប្យូម ដែលមានសមត្ថភាពស្រូប និងភ្ជាប់អាសូត (N) សេរីពី បរិយាកាស និងក្នុងដី។ ទម្រង់ស្លឹកមានលក្ខណៈពិសេសងាយរលួយនៅក្នុងដី ដែលជាប្រភពជីធម្មជាតិដ៏ប្រសើរសម្រាប់ ដំណាំផ្សេងៗទៀត។ ផ្កាជាកញ្ចុំ ពេលរីកមានពណ៌លឿង ផ្លែមានរាងជាស៊ីឡាំងមូលទ្រវែង ផ្លែខ្ចីមានពណ៌បៃតងចាស់ និងផ្លែទុំមានពណ៌ខ្មៅ។ គ្រាប់មានពណ៌បៃតង ចំនួនផ្លែក្នុង ១ ដើមពី ១២-២០ ផ្លែ។ ចំនួនគ្រាប់ក្នុងមួយផ្លែពី ៧-១២ គ្រាប់ ទម្ងន់ ១០០០ គ្រាប់ស្មើនឹង ៧៤.៧ ក្រាម និងទិន្នផលជាមធ្យម ០.៦១ តោនក្នុងមួយហិកតា និងមានសក្តានុពលទិន្នផល ១,៩០ តោនក្នុងមួយហិកតា។

## វិធីសាស្ត្រដាំដុះ

ពូជសណ្តែកបាយនេះ អាចដាំដុះបានពេញមួយឆ្នាំនៅតាមតំបន់ខ្ពង់រាបដោយបុកដាំជាជួរ ឬដាំតាមចង្អូរ និងដាំដោយព្រោះគ្រាប់ ទៅលើដីដែលភ្ជួររួចហើយរាស់លប់។ ចំពោះការដាំដោយបុករណ្តៅជាជួរគួរប្រើ គម្លាតគុម្ព ២៥-៣០ ស.ម គុណនឹង ៣៥-៤០ ស.ម និងជម្រៅពី ២-៣ ស.ម ដោយក្នុងមួយរណ្តៅដាក់គ្រាប់ចំនួន ២-៣ គ្រាប់។ រីឯការដាំតាម តំបន់ទំនាបគឺដាំបន្ទាប់ពីច្រូតស្រូវវស្សារួច ត្រូវលើករងចម្ងាយពីគ្នាប្រហែល ៣០ ស.ម និងមានកម្ពស់ ១០ ទៅ ១៥ ស.ម។ ការដាំដុះពូជសណ្តែកបាយលើផ្ទៃដីមួយហិកតា គឺបើដាំដោយបុកដាំជាជួរត្រូវការគ្រាប់ពូជពី ១៥-២០ គ.ក្រ/ហ.ត និងបើដាំដោយ ព្រោះត្រូវការគ្រាប់ពូជពី ៣០-៤០ គ.ក្រ/ហ.ត។








ក្រោយពីដាំបាន ១០-១៥ ថ្ងៃ គួរកាត់ រំលោះកូនដោយទុក តែដើមណាដែលថ្លោស និងរឹងមាំល្អជាងគេចំនួន ១-២ ដើម ក្នុងមួយគុម្ពចៀសវាងការដណ្ដើមជីជាតិពីដំណាំដែលនាំឲ្យដំណាំលូតលាស់យឺត។ ត្រូវដកស្មៅចង្រៃឲ្យបានស្អាត ចៀសវាងការដណ្ដើមជីជាតិពីដំណាំដែលនាំឲ្យដំណាំដុះលូតលាស់យឺត។

## ការដុះលូតលាស់

ការធ្វើដីបានផុសល្អ ដីមានជីជាតិសំណើមគ្រប់គ្រាន់ និងធាតុអាកាសអំណោយផល ក្រោយពីដាំបាន ៣ ថ្ងៃ គ្រាប់ចាប់ផ្ដើមដុះទូលដីមកខាងលើ។ ចាប់ពីពេលដុះពន្លកហូតដល់អាយុ ១៥ ថ្ងៃសណ្ដែកមានការដុះលូតលាស់ពុំសូវលឿន ប៉ុន្មានទេតែអាយុកាលចាប់ពី ២០ ថ្ងៃឡើងទៅ សណ្ដែកបាយមានការដុះលូតលាស់យ៉ាងលឿន។

| ឈ្មោះដី | កម្រិតជីទៅតាមក្រុមដី (គ.ក្រ / ហ.ត) | | |
|---|---|---|---|
| | ព្រៃខ្មែរ ប្រទះឡាង (ដីខ្សាច់-ល្បាយខ្សាច់) | កំពង់សៀម ឡាបានសៀក ទូលសំរោង (ដីល្បាយឥដ្ឋ) | កៀនស្វាយ (ដីល្បាយ) |
| ដេអាប៉េ | ១០០ | ១១០ | ៨៥ |
| ប៉ូតាស្យូម | ៥០ | ៥០ | ៥៥ |

## ការប្រើប្រាស់ជី

ការប្រើប្រាស់ជីតាមបច្ចេកទេស និងត្រឹមត្រូវតាមពេលវេលាធ្វើឲ្យដំណាំដុះលូតលាស់ល្អទទួលបានទិន្នផលខ្ពស់។ ជីដែលអាចប្រើប្រាស់គឺជី ដេអាប៉េ និងប៉ូតាស្យូម។ ការប្រើប្រាស់ជី គឺជីដេអាប៉េ និងប៉ូតាស្យូម (១០០ ភាគរយ) ដាក់ទ្រាប់បាតមុនពេលដាំ ១ ទៅ ២ ថ្ងៃ។ ជីត្រូវដាក់ដោយភ្ជួរលុបក្នុងជម្រៅ ៥-១០ ស.ម ការពារជីមិនឲ្យបាត់បង់ តាមរយៈការហើរទៅក្នុងបរិយាកាស និងការហូរច្រោះដោយសារទឹកផង។ ចំពោះជីលាមកគោ ឬកំប៉ុស្តិ៍ កសិករ អាចប្រើ នៅពេលទ្រាប់បាតក្នុងកម្រិត ៥ ត/ហ.ត ឬ ០,៥ គ.ក្រ/ម$^2$ បន្ថែមលើជីគីមី បើសិនជាដី របស់គាត់ខ្វះ សារធាតុសរីរាង្គ។

## ការប្រមូលផល

ផ្លែសណ្ដែកទុំអាចប្រមូលផលនៅរយៈពេល ២០ ថ្ងៃក្រោយចេញផ្កា (ចំនួនផ្លែលើសពី ៩០ ភាគរយ ចាប់ផ្ដើមប្រែពណ៌ពីបៃតងក្រមៅទៅជាខ្មៅ)។ គេអាចប្រមូលផលបាន ២-៣ លើក ក្នុងមួយវដ្ដជីវិតរបស់វា។ គម្លាតពេលប្រមូលផលពីមួយលើកទៅមួយលើកមានរយៈពេល ៥-៧ថ្ងៃ។ ប៉ុន្តែការប្រមូលផលលើកទីបី ពុំសូវទទួលបានទិន្នផលច្រើនដូចលើកទីមួយ និងទីពីរទេ។ ការយឺតយ៉ាវក្នុងការប្រមូលផល ជាហេតុធ្វើឲ្យទិន្នផលមានការបាត់បង់ដោយសារផ្លែទុំប្រេះនាំឲ្យជ្រុះគ្រាប់នៅរដូវប្រាំង ឬគ្រាប់សណ្ដែកអាចដុះនៅក្នុងផ្លែបើមានភ្លៀងធ្លាក់ជាប់យូរថ្ងៃនៅរដូវវស្សា។

## ការទុកដាក់ក្រោយប្រមូលផល

ជាមធ្យមសំណើមគ្រាប់ក្រោយពេលប្រមូលផលពី ១៥-១៨ ភាគរយ ដូច្នេះតម្រូវឲ្យយើងធ្វើការហាលសម្ងួតបន្ថែមទៀតដោយកម្ដៅថ្ងៃ។ ការយឺតយ៉ាវក្នុងការហាលសម្ងួតក្រោយពេលប្រមូលផល និងការទុកដាក់គ្រាប់មិនបានត្រឹមត្រូវ គឺងាយរងការបំផ្លាញពីពពួកសត្វល្អិតចង្រៃ ដូចជាខ្មូតជាដើម ដោយវាស៊ីចោះផ្នែកខាងក្នុងរបស់គ្រាប់ដែលធ្វើឲ្យមានការបាត់បង់ទាំងទិន្នផលគុណភាព និងតម្លៃ។




## ការរក្សាទុកគ្រាប់ពូជ

ពូជសណ្ដែកបាយនេះ ជាពូជដែលមានស្ថេរភាពសេនេទិច និងអាចរក្សាទុកគ្រាប់ពូជដាំបានទៀតពី ២-៣ រដូវកាល ប្រសិនបើយើងធ្វើការបន្សុទ្ធពូជបានត្រឹមត្រូវ។ ការរក្សាទុកគ្រាប់ពូជសម្រាប់ប្រើប្រាស់នៅរដូវបន្ទាប់ គឺគ្រាប់ពូជត្រូវមានសំណើមពី ១២-១៣ ភាគរយ ហើយត្រូវរក្សាទុកនៅកន្លែងដែលគ្មានសត្វល្អិត គ្មានខ្យល់ចេញចូល ឬទុកនៅក្នុងធុងបិទជិត ឬអាចរក្សាទុកដោយប្រើប្រាស់ថ្នាំការពារសត្វល្អិត។

សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យរុក្ខជម្រើសវិទ្យា មជ្ឈមណ្ឌលបណ្ដុះបណ្ដាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្ដោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ

ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៥ គេហទំព័រ: www.cardi.org.kh

ទូរអក្ខរ: PBREED@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh